FAMILY RELATIONSHIP ADVICE LINE
HELPING FAMILIES BUILD BETTER RELATIONSHIPS

An Australian Government Initiative

# ខ្សែទូរស័ព្ទដំបូន្មានទំនាក់ទំនងគ្រួសារ

**ការជួយគ្រួសារនានាអោយកសាងទំនាក់ទំនងកាន់តែល្អ**

## 1800 050 321

- ការពង្រឹងទំនាក់ទំនងគ្រួសារ
- ការជួយគ្រួសារនានាអោយស្នាក់នៅជាមួយគ្នា
- ការជួយគ្រួសារនានាដែលឆ្លងកាត់ការបែកគ្នា

## តើអ្វីទៅជាខ្សែទូរស័ព្ទដំបូន្មានទំនាក់ទំនងគ្រួសារ ?

ខ្សែទូរស័ព្ទដំបូន្មានទំនាក់ទំនងគ្រួសារគឺជាសេវាទូរស័ព្ទជាតិ ដែលផ្តល់ព័ត៌មាននិងការបញ្ជូនយោងទៅសេវានានាដែលអាចជួយពង្រឹងទំនាក់ទំនង ជំនះនូវការលំបាកនានានៅក្នុងទំនាក់ទំនង ឬដោះស្រាយការបែកគ្នា។ នៅទីណាដែលសមស្រប ដំណោះស្រាយទំនាស់គ្រួសារក៏ អាចត្រូវបានផ្តល់ជូនផងដែរ។ អ្នកជំនាញដែលមានបទពិសោធន៍ក៏មានដើម្បីជួយមនុស្សដែលរងផលប៉ះពាល់ដោយការបែកគ្នាដោយធ្វើការតាមរយៈ បញ្ហានានាដែលពួកគេកំពុងប្រឈម និងធ្វើសេចក្តីសំរេចចិត្ត តើត្រូវធ្វើអ្វីបន្ទាប់ទៀត។

សេវានានាដែលបានផ្តល់ជូនដោយខ្សែទូរស័ព្ទដំបូន្មានទំនាក់ទំនងគ្រួសារគឺផ្តោតទៅលើកូនៗជាដំបូង និងដោះស្រាយ ទំនាស់នានាស្តីពីកូនៗដោយមិនទៅតុលាការ។ នេះមានន័យថាវិធីសាស្រ្តសហការមានកាន់តែច្រើនរវាង ឪពុកម្តាយដែលបែកគ្នា។

## តើនរណាអាចហៅខ្សែទូរស័ព្ទផ្តល់ដំបូន្មាន ?

នរណាក៏អាចហៅខ្សែទូរស័ព្ទផ្តល់ដំបូន្មានបានស្តីពីទំនាក់ទំនងគ្រួសារ។ នេះរួមមាន ឪពុកម្តាយ ជីដូនជីតា កូនៗ មនុស្សក្មេង សមាជិកគ្រួសារដទៃទៀត ឬមិត្តភ័ក្រ្តនានា។
មនុស្សដទៃទៀតដែលអាចត្រូវផ្តល់នូវដំបូន្មាន ឬការជួយឧបត្ថម្ភដល់គ្រួសារនានាក៏អាចទូរស័ព្ទខ្សែទូរស័ព្ទផ្តល់ដំបូន្មានដើម្បីបានព័ត៌មានដែលអាចជួយបាន។

## តើអ្វីខ្លះជាការរំពឹងទុកនៅពេលខ្ញុំហៅទូរស័ព្ទ ?

នៅពេលដែលលោកអ្នកហៅខ្សែទូរស័ព្ទផ្តល់ដំបូន្មានទំនាក់ទំនងគ្រួសារ លោកអ្នកនឹងអាចនិយាយទៅកាន់នរណាម្នាក់ ដែលអាចជួយលោកអ្នកគិតគូរ តើព័ត៌មានការជួយឧបត្ថម្ភនិងសេវាអ្វីខ្លះដែលលោកអ្នកត្រូវការ។ នេះអាចរួមមានៈ

- ព័ត៌មានស្តីពីសេវានានាដើម្បីជួយរក្សាទំនាក់ទំនងអោយ មានភាពល្អ
- ផ្តល់ដំបូន្មានស្តីពីបញ្ហានានាទាក់ទងនឹងការបែកគ្រួសារ
- ផ្តល់ការណែនាំស្តីពីការបង្កើតនូវការរៀបចំចាត់ចែងធ្វើជា ឪពុកម្តាយដែលអាចដំណើរការបានក្រោយពីការបែកគ្រួសារ
- ផ្តល់ដំបូន្មានស្តីពីផលប៉ះពាល់នៃជម្លោះទៅលើកូនៗ
- ដំណោះស្រាយទំនាស់គ្រួសារតាមមូលដ្ឋានទូរស័ព្ទសំរាប់មនុស្សដែលត្រូវការជំនួយដើម្បីដោះស្រាយទំនាស់លើការ រៀបចំចាត់ចែងធ្វើជាឪពុកម្តាយ
- ការបញ្ជូនយោងទៅមជ្ឈមណ្ឌលទំនាក់ទំនងគ្រួសារនិងសេវា ដំណោះស្រាយទំនាស់នានាផ្សេងទៀត
- ព័ត៌មានស្តីពីប្រព័ន្ធច្បាប់គ្រួសារ
- ការបញ្ជូនយោងទៅបណ្តាសេវាដទៃផ្សេងទៀតដើម្បីជួយជាមួយនឹងទំនាក់ទំនងគ្រួសារនិងបណ្តាបញ្ហាបែកគ្នានានា។

នៅក្នុងអំឡុងពេលមួយនៃការបែកបាក់ មនុស្សជាច្រើនបានប្រឈមជាមួយនឹងភាពចំរុះស្មុគស្មាញនៃបញ្ហាអារម្មណ៍និង ការអនុវត្តន៍។

ខ្សែទូរស័ព្ទផ្ដល់ដំបូន្មានទំនាក់ទំនងគ្រួសារនឹងជួយលោកអ្នកដោះស្រាយបញ្ហាទាំងនេះ និងបញ្ជូនយោងទៅសេវា ដទៃទៀតដែលអាចជួយបាន។ នេះរួមមាន សេវានានាពី Centrelink ទីភ្នាក់ងារឧបត្ថម្ភគាំទ្រ កុមារ ឬសេវាផ្នែកច្បាប់។ វាក៏អាចរួមមានសេវានានាដែលអាចជួយជាមួយនឹងការពិគ្រោះយោបល់ និងឧបត្ថម្ភគាំទ្រសំរាប់លោកអ្នក និងកូនៗ ឬជួយរឿងកន្លែងស្នាក់នៅ បញ្ហាសុខភាពផ្លូវចិត្ត ឬថ្នាំញៀន និងបញ្ហារំលោភបំពានដោយគ្រឿងស្រវឹង។ ខ្សែទូរស័ព្ទផ្ដល់ដំបូន្មានទំនាក់ទំនងគ្រួសារក៏អាចផ្ដល់ជំនួយ និងការបញ្ជូនយោងសំរាប់គ្រួសារទាំឡាយដែលទាក់ទងទងនឹងអំពើហឹង្សា និងបញ្ហារំលោភបំពានកូន។

ដំណោះស្រាយទំនាស់គ្រួសារតាមមូលដ្ឋានទូរស័ព្ទអាចមិន សមស្របសំរាប់មនុស្សទាំងអស់ទេ ហើយបុគ្គលិកផ្ដល់ដំបូន្មានតាមខ្សែទូរស័ព្ទនឹងវាយតម្លៃអ្នកហៅទូរស័ព្ទនិមួយៗ និងផ្ដល់ការបញ្ជូនយោងទៅសេវាសមស្របបំផុត។

## តើខ្ញុំត្រូវផ្ដល់ឈ្មោះរបស់ខ្ញុំឬទេ?

លោកអ្នកមិនចាំបាច់ផ្ដល់ឈ្មោះពេញរបស់លោកអ្នកទេ។ ទោះបីយ៉ាងណាក៏ដោយ នៅពេលលោកអ្នកហៅទូរស័ព្ទ លោកអ្នកនឹងត្រូវបានគេសួរសេចក្ដីពិស្ដារខ្លះដែលនឹងជួយ កំណត់អត្តសញ្ញាណលោកអ្នក ប្រសិនបើលោកអ្នកហៅ ទូរស័ព្ទម្ដងទៀត។ នេះនឹងមានន័យថាលោកអ្នកមិនចាំបាច់ត្រូវនិយាយឡើងវិញនូវព័ត៌មានដដែលនៅពេលលោកអ្នកទូរស័ព្ទម្ដងៗទេ។

ជាជំនួស លោកអ្នកអាចជ្រើសរើសមិនផ្ដល់នូវព័ត៌មានកំណត់អត្តសញ្ញាណណាមួយ និងមិនត្រូវបានចាត់ទុកថាជាអ្នកហៅទូរស័ព្ទថ្មីនៅពេលលោកអ្នកហៅទូរស័ព្ទនៅពេលបន្ទាប់។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមទៀតនៅទីកន្លែងណា?

សំរាប់ព័ត៌មានឥតគិតថ្លៃ ដំបូន្មាន ឬការបញ្ជូនយោង

**ហៅទូរស័ព្ទ**

ខ្សែទូរស័ព្ទផ្ដល់ដំបូន្មានទំនាក់ទំនងគ្រួសារ

**1800 050 321**

8 ព្រឹក- 8 ល្ងាច ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ

10 ព្រឹក- 4 ល្ងាច នៅថ្ងៃ សៅរ៍ (ម៉ោងតាមមូលដ្ឋាន)

លើកលែងតែថ្ងៃឈប់សំរាកជាតិសាធារណៈ។

ឬសំរាប់ព័ត៌មានស្តីពីទំនាក់ទំនងគ្រួសារ និងសេវានានាដែល អាចជួយបាន។

**ទស្សនា**

ទំនាក់ទំនងគ្រួសារតាមអនឡាញ នៅឯ www.familyrelationships.gov.au